ឧបសៅ សង្ហា

# តើមហាអំណាចចិនជាមិត្តល្អរបស់ស្រុកខ្មែរឬទេ?



## មាតិការឿង


លក្ខណៈជាទូទៅ .......... 2

នយោបាយការបរទេសចិន .......... 2

ការទំនាក់ទំនងជាត្រីកោន រវាង ខ្មែរ ចិន យួន .......... 5

សេចក្ដីសនិដ្ឋាន .......... 7


២០ តុលា ២០១៥

# គំនិតចាក់ស្ទូត្រ

## លក្ខណៈជាទូទៅ

សាធារណរដ្ឋ ចិនប្រជាមានិត ជា មហាអំណាច។ កាលដើម គ្រាន់ ជា មហាអំណាច រូបសាស្ត្រ មានទឹកដី ធំទូលាយ និង មាន ចំនួន ប្រជាជន ច្រើនសម្បើម ១,៣១៦ កោត។ បច្ចុប្បន្ននេះ បានក្លាយជា មហាអំណាច សេដ្ឋកិច្ច មាន ឥទ្ធិពលខ្លាំងក្លា លើសេដ្ឋកិច្ច ក្នុង ពិភពលោក។ ហើយ គេដឹងថា នៅមុខជម្រើស នៃ អត្ថប្រយោជន៍ ចិន និង ការរីកចំរើនលូតលាស់ នៃសិទ្ធិមនុស្ស ចិន តែងតែ ជ្រើសរើសអត្ថប្រយោជន៍ចិន មុនជានិច្ច។

នៅក្នុងពិភពលោក សព្វថ្ងៃនេះ មាន បែងចែកជា ច្រើនក្រុមប្រទេស។ សហរដ្ឋអាមេរិក គេទុក ជា មហាអំណាច តែមួយគត់ ដែលគេ អោយ ឈ្មោះថាមហាអំណាចគ្រប់គ្រាន់[1] (mégapuissance)។ តើវា ខុសគ្នា បែបណា នៃស័ព្ទ ទាំង ពីរ នេះ៖ មហាអំណាច នឹង មហាអំណាច គ្រប់គ្រាន់។ មហាអំណាចគ្រប់គ្រាន់ វាមានបរិមាត្រ គោលដៅ រីឯស័ព្ទ មហាអំណាច វាលើកតែ សញ្ញាណ នៃ ឧត្តមភាព មកបង្ហាញ គឺថា ជាបរិមាត្រនៃការគ្រោបសង្កត់តែប៉ុណ្ណោះ។ ក្រុមប្រទេសទី២ មានប្រទេស ដែលមាន ចំនួនប្រជាជនសន្ធឹក គឺរាប់ ពីចំនួន ចាប់ពី ១កោត កម្លះ ទៅ ដូចជា ប្រទេសចិន និង ឥណ្ឌា។ ក្រុមទី៣ គឺជាប្រទេសដែលមាន ការជឿនលឿន ក្នុងផ្នែក ឧស្សាហកម្ម ហើយ មាន ចំនួនប្រជាជនជាមធ្យម ពី ៦០ លាន ទៅ ១៥០ លាន ដូចជា ប្រទេស ជប៉ុន អាឡឺម៉ាញ និង បារាំង។ បន្ទាប់មក គឺ ប្រទេសឧស្សហកម្ម ដូចយ៉ាង ចក្រភពអង់គ្លេស ប្រទេស អ៊ីតាលី អេស្ប៉ាញ។ ទីបញ្ចប់គឺ ពួក ឧទ័យប្រទេស (pays émergents) មានប្រទេស ប្រេស៊ិល និងម៉ិចស៊ិច។

## នយោបាយការបរទេសចិន

ប្រទេសចិន ជាប្រទេស មាន វ័យចាស់ រាប់ពាន់ឆ្នាំ ដែលគេ ចែកជា ៣ជំនាន់៖ ចិនបុរាណ, ចិនកុម្មុយនិស្ត និង ចិន បច្ចុប្បន្ន។

### ចិនបុរាណ

អ្នកដឹកនាំចិន តែងតែ ទុក ប្រទេសខ្លួន ជា មជ្ឈឹមប្រទេស នៃលោក ហើយមាន វត្ថុធាតុ ៣យ៉ាង៖ ដែលជាវត្ថុធាតុ សំខាន់ ដែលនាំឲប្រជាជនចិន មិនសូវយកចិត្ត

[1] មហាអំណាចគ្រប់គ្រាន់ (Mégapuissance)។ មានឥទ្ធិពលយោធា សេដ្ឋកិច្ច វប្បធម៌ នៅក្នុងពិភពលោក ហើយអាចធ្វើអន្តរាគមបានយ៉ាងរហ័ស ណោគ្រប់ទីកន្លែង មិនចាំបាច់មានជំនួយជាសម្ភារៈ ប្រាជ្ញា ពីប្រទេសដទៃ។

ទុកដាក់ ចំពោះប្រជាជនដទៃទៀត ដោយសារខ្លួន យល់ឃើញថា ប្រទេសចិនមាន សមុទ្រ មាន មហាបព៌ (Chaîne de montagne) ខ្ពស់ មាន វាលខ្សាច់ធំល្វឹងល្វាយឡោមព័ទ្ធ ប្រទេសខ្លួន ដែលនាំឲខ្លួន មិនអាចដឹងថា មាន អត្ថភាព នៃជនជាតិដទៃទៀត ក្រៅពីប្រជាជន នៅក្បែរខ្លួន ដែលខ្លួន ឲឈ្មោះគេថា ជាប្រជាជនគ្មានអារ្យធម៌។ ការយល់ឃើញ បែបនេះ ដែលនាំឲ ប្រជាជនចិន មានជំនឿថា អារ្យធម៌ របស់ខ្លួនមានឧត្តមភាព លើសជនជាតិដទៃ ដូច្នេះ វាគ្មានចំណេះអ្វីផ្សេងទៀត ដែលតម្រូវឲខ្លួនរៀនសូត្រ ពីជនជាតិ ដទៃឡើយ។ ដោយ មាន ជំនឿ ខ្លាំងក្លា ទៅលើ ឧត្តមភាព នៃអារ្យធម៌ របស់ ប្រជាជនចិន បានជា ជា វរជនចិន នៅក្នុងសម័យ ដែលប្រទេសខ្លួន ស្ថិតនៅក្រោម ការត្រួតត្រា នៃ ជនជាតិ ម៉ុងហ្គោល ជឿជាក់ថា មិនយូរ មិនឆាប់ ពួកអ្នកដែលមកត្រួតត្រាខ្លួន នឹងយក វប្បធម៌ចិន មកធ្វើជា វប្បធម៌ខ្លួន ព្រោះវប្បធម៌របស់ខ្លួន វា មានភាព អន់ជាង វប្បធម៌ ចិន។ ជំនឿនេះ វាមានកើតពិតប្រាកដមែន ព្រោះជនបរទេស ដែលមកត្រួតត្រាចិន ក៏រលាយសូន្យ ទៅក្នុងសង្គមចិន តែម្តង។

ទ្រឹស្តី កិច្ចការ បរទេសចិន តាំងពីយូរ អង្វែងមក គឺឈរនៅលើ ឧត្តមភាព នៃអារ្យធម៌ ចិន លើ អារ្យធម៌ អ្នកដទៃ៖ អ្នកនាំសារ នៃ ព្រះចៅអធិរាជ្យចិន ទៅបរទេសដើម្បីធ្វើការចរចារ តែងតែមានគំនិត ជានិច្ច ថាខ្លួន មិនមែន មកធ្វើចរចារជាមួយមហាក្សត្រ បរទេស តែជា អ្នកមកបង្ខំ ឲទទួលគោរព ឧត្តម អារ្យធម៌ ចិន និងឲ ចុះចូលនៅក្រោម អំណាច ព្រះចៅ អធិរាជ្យ ចិន។ នៅក្នុង គោលការណ៍ បែបនេះ ដែលចិនមិនរក ដំណោះស្រាយ ជាមួយ ប្រទេស ដទៃ នៅក្នុងភាព ស្មើគ្នា តែគ្រាន់តែ កុំអោយមានភាពល្អៀង តែប៉ុណ្ណោះ។

ដើម្បីការពារ ទល់ដែន របស់ខ្លួន ចិន តែងតែប្រើ វិធី ដ៏ចាស់មួយ គឺ បំបែកដើម្បីស្រួលត្រួតត្រា ដូចយ៉ាង ញុះញង់ ដល់ពួកកុលសម្ព័ន្ធ អោយ វាយប្រយុទ្ធគ្នា ដើម្បីទាញយក ចំណេញ ពី ជម្លោះ នេះ។ ឧទាហរណ៍ នៅក្នុង សន្តតិវង្ស ហាន់ គេប្រើល្បិច ដើម្បីការពារ ទល់ដែន ខាងជើង និង ត្បូង ដែល មាន ឈ្មោះថា «នុយប្រាំ»។ ឧបាយកលនោះ គឺសូក ពួក មហាក្សត្រ នៃ រាជាណាចក្រ Xiongnu៖ ថ្វាយ សម្លៀកបំពាក់ និងព្រះរាជរថ ដ៏វិចិត្រ ដើម្បី លំអរភ្នែក- អាហារសិល្បៈ ដ៏មាន រស់ជាតិ ដើម្បី សប្បាយមាត់ - អោយ ស្តាប់ ចម្រៀង និង តន្ត្រី ដ៏ គោរម មាន នាថការី ឆើតឆាយ រាំកំដរ ដើម្បី ឲសប្បាយត្រចៀក - សង់ ប្រាសាទល្អ ថ្វាយ ហើយ ផ្តល់ នូវធុញ្ញជាតិ និង ទាសករ ដើម្បីបង្អូរ - ធ្វើការជប់លៀង ជាមួយ ព្រះចៅអធិរាជ ដើម្បី បញ្ជោរអារម្មណ៍។

នៅក្នុង សតវត្សទី១៩ ប្រទេសចិន ត្រូវបាន ពួកមហាអំណាច កាន់កាប់ ទឹកដីចិនមួយចំណែកធំ។ ពួក មស្ចឹមប្រទេស និង ប្រទេស ជប៉ុន មាន សេរីភាព និង ឯកសិទ្ធិទទួលបានដី សម្បទាន ដែលគេអោយ ឈ្មោះថា «ដីសម្បទាន អន្តរជាតិ» នៅ ក្នុងទីក្រុង Shanghai។ នៅក្នុងឆ្នាំ ១៩០១ រាជធានី Pékin ត្រូវបានកងទ័ព នៃមហាអំណាចចូលកាន់កាប់ ហើយនៅពេលនោះ អធិរាជនី Ts’eu-Hi ដែលជាសត្រូវ ដាច់ខាតនឹង

គ្រប់រូបភាព នៃកំណែទំរង់ ស្វែងរក មធ្យោបាយ គ្រប់បែបយ៉ាង ដើម្បី តទល់នឹងពួក អ្នកកាន់កាប់ ដូចធ្លាប់ មាន នៅក្នុង ប្រវត្តិសាស្ត្រ ប្រទេសចិន ធ្វើ ការតស៊ូប្រឆាំង នឹង បរទេសឈ្លានពាន។

## ចិនកុម្មុយនិស្ត

នយោបាយ ការបរទេសចិន កុម្មុយនិស្ត ក្នុងកំឡុង ឆ្នាំ ១៩៤៩-១៩៥២ គឺ ឈរលើ ការស្វែងរក ជំនួយគ្រប់វិស័យ ពីសំណាក់ សហភាព សូវៀត ដើម្បី ធ្វើអភិវឌ្ឍន៍ សេដ្ឋកិច្ច និង ជួយការពារ សាធារណរដ្ឋចិនប្រជាមានិតគ្រប់រូបភាព នូវការឈ្លានពាន ពីសំណាក់ មហាអំណាច លោកសេរី មាន សហរដ្ឋអាមេរិក ជាអាថ៍។ តែក្រោយមកមាន កើតជម្លោះ រវាងចិន នឹង សហភាពសូវៀត រុញច្រាន ចិនកុម្មុយនិស្ត ឲស្វែងរកសមតា ក្នុងទំនាក់ទំនង ប្រទេសចិន លើឆាក អន្តរជាតិ។ ការចាប់ដៃ សហរដ្ឋអាមេរិក គឺចុះនាម (s'inscrit) ក្នុងនយោបាយ រកសមតា។ ការចូលរួមបង្កើត អង្គការ នៃប្រទេស មិនចូល ក្នុងប្រតិព័ន្ធ លោក សេរី និង កុម្មុយនិស្ត ដែលមាន សហរដ្ឋអាមេរិក និង សហភាព សូវៀតជា អ្នកដឹកនាំ គឺជា ការស្វែងរក តួនាទី ជាអ្នកដឹកនាំ នៅក្នុងតតិយលោក ដើម្បីអះអាង នូវអត្តភាព នៃប្រទេសចិន លើឆាកអន្តរជាតិ។ ការចូលរួមធ្វើ សង្គ្រាម នៅប្រទេស កូរ៉េ ខាងជើង និង ជួយ ឧបត្ថម គ្រប់ មធ្យោបាយ ដល់យួន កុម្មុយនិស្ត ធ្វើសង្គ្រាម ប្រឆាំង អាមេរិកាំង នៅយៀកណាម ក៍ជាការស្វែងរកកន្លែង អង្គុយ ជា ទិស្សមាន នៅក្នុង លោក កុម្មុយនិស្ត។ ចិន កុម្មុយនិស្ត ក៍ដូច ចិនបូរាណ នៅតែ មាន ជំនឿ លើ ឧត្តមភាព នៃវប្បធម៌ចិន ពាន់ឆ្នាំ លើស វប្បធម៌ នៃជាតិ សាសន៍ដទៃ នៅក្នុង ពិភពលោក។ ចិន កុម្មុយនិស្ត តែងតែ ប្រើ យុទ្ធសាស្ត្រ «នុយប្រាំ» គឺ បំប៉េក ដើម្បី ស្រួល ត្រួតត្រា តាមការ ញុះញង់ ដល់ សព្វប្រទេស នៅក្នុង ដែន ឥទ្ធិពលចិន។

## ចិនបច្ចុប្បន្ន

ចិនបច្ចុប្បន្ន ជា មហាអំណាច សេដ្ឋកិច្ច អះអាង គ្មានសាំញ៉ាំ (sans complexe) នូវ ឧត្តមភាព នៃវប្បធម៌ចិន រហូត មានលក្ខណៈជា សេយ្យមានៈ ជាទិស្សមាន នៅក្នុងពិភពលោក។ អាកប្បកិរិយា នេះ ជាផលផ្ទាល់ នៃ ការរីកចំរើន សេដ្ឋកិច្ចជាក់ស្តែងដែល អាចឲប្រទេសចិន ដើរតួជានាយទុនធំ នៅក្នុងសកម្មភាព សេដ្ឋកិច្ច និង ពាណិជ្ជកម្ម ពិភពលោក។ ចិន ប្រព្រឹត្តិ នយោបាយទូត បែប នយោបាយប្រាកដនិយម[2] ជាមួយ នឹង ការប្រើ យុទ្ធសាស្ត្រ «នុយប្រាំ» ដើម្បីរកតែចំណេញជានិច្ច។ ចិនបច្ចុប្បន្នអនុវត្តន៍ លទ្ធិកុម្មុយនិស្ត គ្មានខ្ចោះ ក្នុងនយោបាយ ផ្ទៃក្នុង តែជា មហាមូលធនិក នៅក្នុងផ្សារ សេរី ពិភពលោក គឺនៅក្នុងទស្សនៈ ប្រទេសតែមួយ មានប្រព័ន្ធពីរ។ ប្រតិបត្តិលទ្ធិកុម្មុយនិស្ត ដើម្បីរក្សាអំណាច គណបក្សកុម្មុយនិស្ត ដែលមានតែមួយ តែប្រើប្រាស់ប្រព័ន្ធ

[2] នយោបាយប្រាកដនិយម = Realpolitik។

ផ្សារ សេរីអន្តរជាតិ ដើម្បី ធ្វើអភិវឌ្ឍន៍សេដ្ឋកិច្ច សំរាប់លើក ដំកើងជីវភាពរស់នៅនៃ ប្រជាជនចិន នៅក្នុង គ្រោង មានកំរិត ដែលគណបក្សកុម្មុយនិស្ត អនុញ្ញាតិ ឲមាន គឺ មានភោគសម្បត្តិ តែ គ្មានសេរីភាពនយោបាយ។

គេអាចសន្និដ្ឋាន បានថា ចិនបូរាណក្តី ចិនកុម្មុយនិស្ត ក្តី និង ចិនបច្ចុប្បន្ន ក្តី ជា ចិន ប្រព្រឹត្តិនយោបាយផ្តាច់ការ ជានិច្ច លើប្រជាពលរដ្ឋ។ អំពើនេះ គេអាចចាត់ទុក វា ជា ថាវរភាព នៃនយោបាយ ផ្ទៃក្នុង របស់ចិន។ ហើយ ការទំនាក់ទំនងចិន ជាមួយ ប្រទេសដទៃ គឺស្ថិត នៅក្នុង គោលការណ៍ ទុកប្រយោជន៍ចិន ជាអាទិភាពដាច់ខាត។ គំនិតនេះ ដែលនាំឲ ប្រទេសចិន ក្លាយជា ពាណិច្ចករ គ្រអឺតគ្រអោង រកតែចំណេញ ជួនតាមការ កេងប្រវ័ញ្ចន៍ ជាពិសេស ពួកនាយទុនចិន មករកស៊ី នៅក្នុងប្រទេស ដែលមិនទាន់លូតលាស់ ដឹកនាំ ដោយ របបផ្តាច់ការ ពុករលួយ។ តើនាយទុនទាំងនោះ ជា អ្នកវិនិយោគ ឬ ជា ឈ្មួញឆ្លៀតឱកាស ?

## ការទំនាក់ទំនងជាត្រីកោន រវាង ខ្មែរ ចិន យួន

ប្រទេស ខ្មែរ និង ចិន ធ្លាប់មាន ទំនាក់ទំនងគ្នា តាំងពីបូរាណកាលមក តែមាន លក្ខណៈ ជា ទំនាក់ទំនង ក្នុង សេចក្តីគួរសម។ នៅក្នុង កំឡុង សតវត្សទី៣ គឺថាក្នុង ចន្លោះឆ្នាំ ២៤៥ និង ២៥០ មាន បេសកម្មចិនមួយ មកធ្វើទស្សនៈកិច្ច នៅនគរ ហ្វូណន់ ហើយចេះតែ មាន បន្តបន្ទាប់មកទៀត រហូតមកដល់ សម័យមហានគរ។ នៅក្នុង ទស្សវត្សរ៍៥០ ប្រទេស ចិនកុម្មុយនិស្ត ទាក់ទាញចិត្ត សម្តេច សីហនុ កុំឲ ព្រះអង្គចូល អង្គារ សន្ធិសញ្ញា នៃប្រទេស អាស៊ីប៉ែកអគ្នេយ៍ (SEATO) ដែលជាអង្គារ ប្រឆាំងកម្លាំង កុម្មុយនិស្តនៅអាស៊ី។ នៅក្នុងឱវាទចិន ដដែល សម្តេច សីហនុ ព្រះអង្គ ចូលរួមយ៉ាង សកម្ម នៅក្នុង អង្គារ នៃប្រទេសមិនចូល ក្នុងប្រតិព័ន្ធណាមួយ។ កិច្ច (acte) ទាំងពីរ នេះ របស់ សម្តេច សីហនុ គឺធ្វើឡើង នៅក្នុង យុទ្ធសាស្ត្រចិន «បំបែក ដើម្បី ងាយ ត្រួតត្រា» ឬ ស្រួលឲ ចិន មានឥទ្ធិពល មកលើខ្មែរ ដើម្បីអាចទាញយកប្រយោជន៍បាន។ នយោបាយ នេះ មាន អនុភាពជាក់ស្តែង គឺ នាំឲ សម្តេច សីហនុ ដូរនយោបាយ ទំនាក់ទំង អន្តរជាតិខ្មែរ ពី អព្យាក្រិត ជា យថាភូត មកជា អព្យាក្រិត លំអៀងទៅរក លោកកុម្មុយនិស្ត ដូចយ៉ាង ឈប់ទទួលជំនួយ អាមេរិកាំង នៅក្នុងឆ្នាំ១៩៦៣តែទទួល ជំនួយ ចិនកុម្មុយនិស្ត ដែល តម្រូវឲខ្មែរគាំពារ យៀកកុង (**រណសិរ្សសេរីការជាតិ**) ដែល ជាកម្លាំងទ័ព យៀកណាម ខាងជើង នៅយៀកណាមខាងត្បូង។ចាប់ពីឆ្នាំ១៩៦៥មក សម្តេច សីហនុ បានអនុញ្ញាត ឲពួកយៀកកុង ប្រើប្រាស់ ទឹកដីខ្មែរ ជាមូលដ្ឋានគំពារ សមរភូមិខ្លួន នៅយៀកណាម ខាងត្បូង។ គេអាច ទុក ចំណុចនេះ ជាការធ្វើឲក្រឡាប់ នយោបាយ អព្យាក្រិត របស់ សម្តេចសីហនុ តែម្តង ដែលនាំសហគមន៍អន្តរជាតិ គេ ទុក អព្យាក្រិតខ្មែរ ជារឿងកំប្លែងមួយរបស់ ខ្មែរ។ ផលវិបាក នៃការប្តូរនយោបាយនេះ

គឺ ការនាំភ្លើងសង្គ្រាម មកដុតនៅក្នុងស្រុកខ្មែរ ព្រោះចាប់ពីឆ្នាំ ១៩៦៥ មក ស្រុកខ្មែរ បានក្លាយជា មូលដ្ឋានសឹក របស់ ពួកយៀកកុង ដែលនាំឲ កងទ័ពអាកាស អាមេរិកាំង ធ្វើការ ទំលាក់ គ្រាប់បែក ដើម្បី កំទេច មូលដ្ឋានយៀកកុង និង ការវាយចូល ជារឿយៗ មកក្នុងទឹកដីខ្មែរ ពីសំណាក់កងទ័ព យួន ខាងត្បូង ដើម្បី តាមវាយ ពួកយៀកកុង ដែលបាន ដើរ ចេញពីស្រុកខ្មែរ ទៅធ្វើប្រតិបត្តិការសឹកនៅយៀកណាមខាងត្បូង រួចហើយក៏នាំគ្នារត់ចូលមកពួនវិញ។ ល្បែងលេងពួន នេះ នាំឲប្រជាជនខ្មែរ ជាច្រើន ទទួល រងគ្រោះ ដល់ជីវិត ព្រោះ ខ្លួន មានទីលំនៅដ្ឋាន នៅក្បែរ មូលដ្ឋានយៀកកុង។ គ្រោះថ្នាក់នេះឯង ដែលនាំ ប្រជាកសិករ ខ្មែរ រស់នៅ ក្នុង តំបន់សឹក យៀកកុង ដូចយាំង នៅ ខេត្រស្វាយរៀង នាំគ្នាបះបោល ទាមទារឲយៀកកុងចេញពីប្រទេសខ្មែរ។នេះហើយ ជារឿងហេតុ នៃព្រឹត្តិការណ៍ ថ្ងៃទី ១៨ មិនា ឆ្នាំ ១៩៧០ ដែល ពួក អ្នកសីហនុនិយម គេទុកជា រដ្ឋប្រហារ។ តាមការពិត វាជា ផលវិបាក នៃនយោបាយ ប្រហារជាតិខ្លួនឯងរបស់ សម្តេច សីហនុ ដោយព្រះអង្គមានជំនឿជាក់ច្បាស់ថា មានប្រទេសចិនកុម្មុយនិស្ត ជា និយតករ[3] ការពារ ប្រយោជន៍ខ្មែរ នៅ ចំពោះ ឥទ្ធិពល យួនកុម្មុយនិស្តនៅកម្ពុជា។

នៅក្នុង សម័យ សាធារណរដ្ឋ ដែល ជា របប ការពារ បូរណភាព ទឹកដីខ្មែរ ពីការឈ្លានពាន ដោយ កម្លាំងអាវុធ ពី សំណាក់ យួនកុម្មុនិស្ត នៅពេលនោះ ប្រទេសចិនគាំពារយ៉ាង មុឺងម៉ាត់ នៃការឈ្លានពាន នេះ ដូចយ៉ាង បង្កើត **រណសិរ្សរួបរួមជាតិនៃកម្ពុជា** ដែលមាន កងទ័ពយៀកកុង ពាក់ឯកសណ្ឋាន ជាខ្មែរ ធ្វើជាទ័ព របស់ រណសិរ្សកែក្រឡៃ សង្គ្រាម ឈ្លានពាន បរទេស ឲក្លាយជា សង្គ្រាមស៊ីវិល។

ប្រទេសចិន ញុះញង់ ពួកខ្មែរក្រហម ឲបន្ត សង្គ្រាម នៅកម្ពុជា ក្រោយ ពី មានកិច្ចព្រមព្រៀង សន្តិភាព នៃ ទីក្រុង បារីស៍ ក្នុងឆ្នាំ ១៩៧៣។ ដែល ជា សង្គ្រាម មួយ នាំចំណេញ ដល់ ពួក យួនកុម្មុយនិស្ត លាក់ទ័ពខ្លួន ជានិច្ច នៅក្នុងជួរទ័ព ពួកខ្មែរក្រហម បន្តសង្គ្រាមវាយទ័ព សាធារណរដ្ឋខ្មែរ ដែលត្រូវ អាមេរិកាំង បោះបង់ ចោលដោយអយុត្តិធម៌ ជាទីបំផុត។ ចិន បោក អាមេរិកាំង បាន ថា ខ្លួនជាអ្នកធានា ឲមានអន្តរភាព នយោបាយ តាមផ្លូវ សន្តិភាព នៅស្រុកខ្មែរ ដោយមាន សម្តេច សីហនុ ជា អ្នកដឹកនាំ ក្នុង ស្មារតី បង្រួបបង្រួមជាតិ។ តែ ការធានា របស់ចិន នេះ ក្លាយជាថ្នាំពុលសំរាប់ប្រជាជាតិខ្មែរ។

ប្រាំឆ្នាំ នៅ ក្នុង របបខ្មែរ ក្រហម ហៅថា «កម្ពុជា ប្រជាធិបតេយ្យ» ចិន ជាអ្នកគាំពារ នៃ នយោបាយ ប្រល័យ ពូជសាសន៍ នៅក្នុងស្រុកខ្មែរ នាំឲ ប្រជាជនខ្មែរជាងពីរលាន បាត់បង់ ជីវិត ដូចសត្វ។ នយោបាយ នេះ បំផ្លាញ កម្លាំង ជាតិខ្មែរ ឲបាត់សូន្យ ដូចដើមឈើពុក គ្រាន់តែត្រូវ កម្លាំង ខ្យល់រដូវ រលំ បាក់ឯងៗ។ ខ្យល់នេះ គឺខ្យល់ ៧ មករា ឆ្នាំ ១៩៧៩ បក់ មកលើ ប្រជាជាតិខ្មែរ ផាត់យកព្រលឹងខ្មែរ នៅសល់តែរូប

[3] **និយតករ**= régulateur។

រាងស្គម កញ្ច្រឹង ជា មនុស្ស ដាច់បាយ រួច នាំគ្នា រើសរក រស់ ជាប្រជាជាតិខ្ញុំយួន ដែលជាកម្លាំង  ខ្យល់រដូវ។ ការរលំ នេះ ជា គរុភាព (ទម្ងន់) មួយ សំរាប់ប្រជាជាតិ រហូតមកដល់បច្ចុប្បន្នកាល។

ចិនកុម្មុយនិស្ត បន្ត ជួយពួកខ្មែរក្រហម ក្រោយពីរបបប្រល័យពូជសាសន៍នេះ ដួលរលំ រត់ ទៅរករស់តាម ព្រំដែន ខ្មែរ/ថៃ។ បន្តធ្វើសង្គ្រាម ក្នុងនាមជាសង្គ្រាមតស៊ូរំដោះជាតិ នាំបន្សាប កម្លាំងតស៊ូ របស់អ្នកស្នេហាជាតិខ្មែរ នៅចំពោះ មុខប្រជាជនខ្មែររស់នៅក្រោមរបបអាណានិគមយួន។ ការរក្សា អង្គារ ខ្មែរក្រហម នៅក្នុង ចលនាតស៊ូខ្មែរ ជា គំនិតខុស មួយ ចំពោះអ្នកស្នេហាជាតិខ្មែរ តែចិន គេយល់ផ្ទុយទៅវិញថាជាកម្លាំងប្រាកដ  របស់  ជាតិខ្មែរ។ ត្រូវដឹងថា កម្លាំង  នេះឯង នាំគ្នា  ចុះ  ចូល ហ៊ុន សែន បន្តសកម្មភាព សម្លាប់ប្រជាពលរដ្ឋខ្មែរ ក្នុងយុទ្ធសាស្ត្រយួន/ចិន ដើម្បីរក្សាលទ្ធិកុម្មុយនិស្តនៅស្រុកខ្មែរ។

កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ ជា ដំណោះស្រាយ នៃ វិវិជ របស់ចិនយួន ក្នុង  ការដណ្តើមយក កម្ពុជា មកដាក់ នៅក្នុង  អំណាច  របស់ខ្លួន។ ពីដើម ចិនចង់បាន កម្ពុជា ដើម្បី ទប់ទល់ យួន រីឯយួន ចង់បានដីខ្មែរ មកធ្វើជាដីយៀកណាម។ តែនៅពេលដែលចិនយួន គេរកឃើញ  រូបមន្ត  មួយ  ត្រូវគ្នា គឺ ចិន យកធនធានធម្មជាតិខ្មែរ រីឯ យួន យកដីខ្មែរ ជា ដីសម្បទាន។ ហើយ ចិន/យួន គេរកស៊ីជាមួយគ្នា លើខ្នងខ្មែរ ចែកជាកម្រៃខ្លះ ឲនាម៉ឺនខ្មែរ ដើម្បី ឲដើរ ហីហារ ធ្វើ ជា អ្នកមាន។ យួនប្រើកិច្ចព្រមព្រៀង ២៣ តុលា ជា មធ្យោបាយ ដើម្បី ធ្វើ  នីត្យានុកូលកម្ម នូវការត្រួតត្រាខ្លួននៅស្រុកខ្មែរ ចំណែក ចិន ប្រើជា កិច្ចព្រមព្រៀង ពាណិជ្ជកម្មរវាងខ្មែរ យួន ចិន រីឯ ពួក មស្ទឹម ប្រទេស ទុក វា ជា ករណីយកិច្ច សីលធម៌ របស់ខ្លួន តែប៉ុណ្ណោះ ធ្វើចប់កាលណា នាំគ្នា  ដើរចេញ ទុកឲ ប្រជាពលរដ្ឋ  ខ្មែរ រស់គ្មាន  សង្ឃឹម នៅក្នុង កិច្ចព្រមព្រៀង ក្រោមគុក របស់ ចិន/យួន ប្តូររូប ស្រុកខ្មែរឲទៅជាឋានសួគ៌ សំរាប់ ថៅកែ និងពួកជនពុករលួយ មួយក្តាប់ តែជា ឋាននរក សំរាប់ប្រជាជនខ្មែរមួយនគរ។

## សេចក្តីសន្និដ្ឋាន

បើយោងទៅលើ  អំពើ  គ្រប់បែបយ៉ាង ដែលបាន  រៀបរាប់ខាងលើនេះ យើងអាចសន្និដ្ឋានបានថា ចិន  កុម្មុយនិស្ត ពិត  ជា  មិត្តល្អ របស់ សម្តេច សីហនុ តែមិនជាមិត្តល្អ របស់ ប្រជាពលរដ្ឋខ្មែរ នោះឡើយ។ សូម  ខ្មែរម្នាក់ៗ យក  វា  ទៅពិចារណា ព្រោះថាវិភាគ របស់យើង គ្រាន់តែ វិស័យមតិ មួយ ក្នុងជំនឿ ជាក់ច្បាស់ថា ចិនកុម្មុយនិស្ត ជាបញ្ហា របស់ ប្រជាជាតិខ្មែរ តាំងពីទស្សវត្សរ៍ ទី៦០ មកម្លេះ។៚